# គោលបំណងនៅពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់
# ពួកជំនុំជាបង្អួច
# God’s Present Intentions
# Church is the Window

**សេចក្តីសង្ខេប:**

ការស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះជាម្ចាស់គឺជាអ្វីដែលព្រះចង់បានពីអ្នកជឿទាំងអស់។ ការដែលយើងស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះគ្រីស្ទបង្ហាញឱ្យឃើញពីសេចក្តីល្អនៃបំណងរបស់ព្រះជាម្ចាស់សម្រាប់សេចក្តីសង្គ្រោះ និងការស្អាងឡើងវិញទាំងនៅពេលអនាគត និងនៅពេលបច្ចុប្បន្ន។ ការមិនស្តាប់បង្គាប់របស់យើងបង្កើតជញ្ជាំងដែលបាំងពិភពលោកមិនឱ្យស្គាល់សេចក្តីស្រលាញ់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ។ ពួកជំនុំប្រៀបបីដូចជា "បង្អួច" ដែលតាមរយៈនោះ ពិភពលោកដែលបាក់បែកអាចមើលឃើញគោលបំណងរបស់ព្រះជាម្ចាស់បាន។

**គំនិតចម្បង:**

១. ព្រះជាម្ចាស់បង្គាប់ប្រជារាស្ត្រព្រះអង្គឱ្យបង្ហាញចេញគោលបំណងដ៏ល្អរបស់ព្រះអង្គនាពេលឥឡូវនេះនៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត។

២. អំពើបាបរបស់យើង គឺការដែលយើងមិនស្តាប់បង្គាប់តាមគោលបំណងនៅពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់បានបង្កើតជញ្ជាំងដែលរារាំងពិភពលោកមិនឱ្យមើលឃើញ និងមិនឱ្យមានបទពិសោធន៍ជាមួយសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់។

៣. នៅពេលដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់ស្តាប់បង្គាប់ព្រះអង្គ ពួកគេត្រលប់ជាបង្អួចដែលតាមរយៈនោះ អ្នកទៃទៀតអាចមើលឃើញគោលបំណងដ៏ល្អរបស់ព្រះជាម្ចាស់ និងត្រូវបានទាញមកឯព្រះអង្គ។

៤. បទគម្ពីរផ្តល់ការប្រៀបធៀបជាច្រើន ដើម្បីពន្យល់អំពីតួនាទីតាមបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកជំនុំនៅលើផែនដីនៅសព្វថ្ងៃនេះ។

**លទ្ធផល:**

១. ឥឡូវនេះ

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. រៀបចំផែនការ និងអនុវត្តជំហានថ្មីមួយជាការឆ្លើយតបទៅនឹងគំនិតចម្បងនៅក្នុងមេរៀននេះ ដើម្បីអនុញ្ញាតឱ្យគេមើលឃើញគោលបំណងដ៏ល្អរបស់ព្រះជាម្ចាស់តាមរយៈការបម្រើដោយសេចក្តីស្រលាញ់តាមបែបសាមញ្ញ។

២. ទៅមុខទៀត

ក. ទទួលស្គាល់ថា ពួកគេមិនបានបង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដល់មនុស្សដទៃទៀត ប្រែចិត្តពីអំពើបាប និងការមិនស្តាប់បង្គាប់របស់ពួកគេ ហើយប្តេជ្ញាចិត្តបង្ហាញចេញគោលបំណងប្រកបដោយក្តីស្រលាញ់របស់ព្រះជាម្ចាស់សម្រាប់ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ខ. ធ្វើការជាអ្នកដឹកនាំដើម្បីប្រាប់ និងលើកទឹកចិត្តប្រជារាស្ត្ររបស់ព្រះជាម្ចាស់ឱ្យមានបំណងបង្ហាញចេញគោលបំណងដ៏ល្អប្រកបដោយសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្ន និងសម្រាប់ពេលអនាគត។

# គោលបំណងនៅពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់

## ពួកជំនុំជាបន្ទូច

### គ្រោងមេរៀន

**១. រំឭកមេរៀនឡើងវិញ**

**២. សេចក្ដីផ្ដើម**

**៣. ខគម្ពីរគន្លឹះ៖ ម៉ាថាយ ៦:៩-១០**

ក. តើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នឹងសម្រេចយ៉ាងគ្រប់លក្ខណ៍នៅឯណា?

ខ. តើយើងត្រូវអធិស្ឋានយ៉ាងដូចម្ដេចអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់?

គ. តើគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្នមានអ្វីខ្លះ?

ឃ. តើអ្វីធ្វើឱ្យមានការខុសប្លែកគ្នារវាងស្ថានសួគ៌ និងផែនដី?

ង. តើមានអ្វីនឹងកើតឡើង ប្រសិនបើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ?

## ៤. តើគោលបំណងនូទៅរបស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្នមានអ្វីខ្លះ?

- យ៉ូហាន ១៤:១៥
- កិច្ចការ ១៣:២២
- ម៉ាថាយ ២៨:១៨-២០

## ៥. តើយើងស្គាល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច?

- ទំនុកដំកើង ១១៩:៩៩-១០០
- សុភាសិត ២:១-៥
- យ៉ូហាន ១៦:១៣

## ៦. តើគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ជីវិតផ្ទាល់ខ្លួនរបស់យើងមានអ្វីខ្លះ?

- កិច្ចការ ១៤:២២
- អេភេសូរ ៥:១៧-២០
- ១ ថែស្សាឡូនីច ៤:៣, ១១

**៧. តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្ដេចខ្លះសម្រាប់គ្រួសាររបស់យើង?**

- អេភេសូរ ៥:២១
- អេភេសូរ ៦:៤

**៨. តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្ដេចសម្រាប់បងប្អូនគ្រីស្ទបរិស័ទ?**

- យ៉ូហាន ១៣:៣៤
- យ៉ូហាន ១៧:២០-២៣

**៩. តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្ដេចសម្រាប់ទំនាក់ទំនងរបស់យើងជាមួយអ្នកដែលនៅក្នុងលោកិយ?**

- រ៉ូម ១៣:៩
- យ៉ាកុប ១:២៧
- យេរេមា ២២:៣, ១៥-១៦

**១០. តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្ដេចសម្រាប់ទំនាក់ទំនងរបស់យើងជាមួយ និយោជក អ្នកបម្រើ និងរដ្ឋាភិបាល?**

- កូល៉ុស ៤:១
- ១ពេត្រុស ២:១៣-១៥
- រ៉ូម ១៣:១

**១១. តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្ដេចសម្រាប់ទំនាក់ទំនងរបស់យើងជាមួយ ខ្មាំងសត្រូវរបស់យើង?**

- លូកា ៦:២៧, ៣៥-៣៦

**១២. សមីការគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្ន**






## ១៣. ពួកជំនុំជាបង្អួច




## ១៤. រូបភាពអំពីពួកជំនុំ

- ចោទិយកថា ៤:៥-៨
- ម៉ាថាយ ៥:១៣-១៦
- យ៉ូហាន ១៧:១៨
- ២កូរិនថូស ៣:២-៣
- ភីលីព ២:៥-៨
- ១ពេត្រុស ២:១២

- រ៉ូម ៨:១៩

## ១៥. ការអនុវត្តន៍

ក. ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

- កត់ត្រាយ៉ាងហោចណាស់សកម្មភាពថ្មីពីរនៅក្នុងផ្នែកនិមួយៗនៃផ្នែកទាំងបួន ដែលពួកជំនុំរបស់លោកអ្នកអាចធ្វើបាន ដើម្បីបង្ហាញគោលបំណងនៅពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់ដល់មនុស្សនៅក្នុងសហគមន៍របស់លោកអ្នក។

***សូមចងចាំ:*** រៀបចំផែនការធ្វើអ្វីមួយ

(ក) ថ្មី

(ខ) ច្បាស់លាស់

(គ) ជាក់លាក់ ( អ្វី នរណា នៅពេលណា នៅកន្លែងណា)

(ឃ) ចែកចាយ

| | |
|---|---|
| **<u>ប្រាជ្ញា</u>** | **<u>ខាងវិញ្ញាណ</u>** |
| **<u>ខាងសាច់ឈាម</u>** | **<u>ខាងសង្គម</u>** |

ខ. ការប្តេជ្ញាចិត្ត និងផែនការៈ

- ចែកចាយគំនិតរបស់លោកអ្នកជាមួយសិស្សផ្សេងទៀត ហើយអធិស្ឋានឱ្យគ្នាទៅវិញទៅមក។
- ជួបជាមួយអ្នកដឹកនាំពួកជំនុំមូលដ្ឋានរបស់លោកអ្នកម្នាក់ ឬច្រើននាក់ ហើយបង្ហាញបញ្ជីរបស់លោកអ្នកឱ្យពួកគេមើល និងពិភាក្សាអំពីភាពដែលអាចធ្វើបានចំពោះគំនិតរបស់លោកអ្នក។

# គោលបំណងនៅពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់

# ពួកជំនុំជាបន្ទូច

តើព្រះជាម្ចាស់មានដំណឹងល្អសម្រាប់ពេលបច្ចុប្បន្នដែរឬទេ? មាន! ដំណឹងល្អរបស់ព្រះអង្គមិនត្រឹមតែសម្រាប់ពេលអនាគតប៉ុណ្ណោះទេ។ សូមគិតអំពីរបៀបដែលព្រះអង្គបានបង្រៀនសិស្សរបស់ព្រះអង្គឱ្យអធិស្ឋានៈ "ឱព្រះវរបិតានៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌អើយ សូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដីដូចនៅស្ថានសួគ៌ដែរ" (ម៉ាថាយ ៦:៩-១០)។ នៅផែនដីដូចជានៅស្ថានសួគ៌ដែរ! យើងប្រហែលជាសូត្រការអធិស្ឋាននេះញឹកញាប់យ៉ាងខ្លាំង រហូតដល់ការអធិស្ឋាននេះត្រលប់ទៅជាគ្មានន័យ។ ការអធិស្ឋាននេះមិនមែនគ្មានន័យទេ ការអធិស្ឋាននេះមានអំណាចខ្លាំងណាស់!

តើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅកន្លែងណា? យោងទៅតាមការអធិស្ឋានរបស់ព្រះអម្ចាស់ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅស្ថានសួគ៌។ ប៉ុន្តែព្រះយេស៊ូវបានបង្រៀនយើងឱ្យអធិស្ឋានសូមឱ្យបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេច*នៅផែនដី*ដូចជានៅស្ថានសួគ៌ដែរ។ ព្រះជាម្ចាស់មានគោលបំណងចង់ឱ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅពេលបច្ចុប្បន្ន នៅលើផែនដីនេះ។ តើមានអ្វីកើតឡើងប្រសិនបើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ? តើមានអ្វីកើតឡើងប្រសិនបើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅក្នុងសហគមន៍របស់លោកអ្នក ឬនៅក្នុងប្រទេសរបស់លោកអ្នក ដូចជានៅស្ថានសួគ៌ដែរ? ផែនដីនឹងបានដូចជាស្ថានសួគ៌! (ប្រាកដណាស់ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចយ៉ាងគ្រប់លក្ខណ៍នៅស្ថានសួគ៌។ នៅលើផែនដី នៅពេលបច្ចុប្បន្ននេះ បំណងព្រះហឫទ័យរបស់ព្រះអង្គបានសម្រេច ប៉ុន្តែមិនទាន់សព្វគ្រប់នៅឡើយទេ)។

## ការស្គាល់គោលបំណង និងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់

តើគោលបំណងទូទៅរបស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្នមានអ្វីខ្លះ? នៅក្នុងយ៉ូហាន ១៤:១៣ យើងមើលឃើញថា ប្រសិនបើយើងស្រលាញ់ព្រះជាម្ចាស់ យើងស្ដាប់បង្គាប់ព្រះអង្គ។ ព្រះជាម្ចាស់មានបំណងព្រះហឫទ័យចង់ឱ្យយើង*ធ្វើតាម*បំណងព្រះហឫទ័យរបស់ព្រះអង្គ! ម៉ាថាយ ២៨:១៨-២០ បញ្ជាក់អះអាងថា ការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់រួមមានការបង្កើតសិស្សផ្សេងទៀតឱ្យស្ដាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះអង្គផងដែរ

ប៉ុន្តែជាញឹកញាប់ មនុស្សគ្រាន់តែចាំមួយផ្នែកនៃកិច្ចការដែលព្រះយេស៊ូវបានប្រទានឱ្យពួកជំនុំរបស់ព្រះអង្គនៅក្នុងមហាបេសកកម្ម គឺឱ្យចេញទៅគ្រប់ទីកន្លែងនៅក្នុងពិភពលោក ហើយប្រកាសដំណឹងល្អ។ ប៉ុន្តែនោះមិនមែនជាភារកិច្ចទាំងមូលទេ។ នោះគ្រាន់តែជាផ្នែកចាប់ផ្តើមប៉ុណ្ណោះ។ ក្រោយពីមនុស្សបានជឿព្រះគ្រីស្ទរួចហើយ យើងត្រូវបង្រៀនពួកគេឱ្យ*ធ្វើតាម*បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ប្រសិនបើយើងមិនបានធ្វើបែបនោះ យើងមិនបានបញ្ចប់ភារកិច្ចរបស់មហាបេសកកម្មឡើយ។ យើងត្រូវតែបង្រៀនអ្នកដទៃទៀតឱ្យធ្វើតាមគ្រប់ទាំងសេចក្តីដែលព្រះជាម្ចាស់បានបង្គាប់ផងដែរ។

តើយើងស្គាល់គោលបំណងរបស់ព្រះជាម្ចាស់បានយ៉ាងដូចម្តេច? យើងមិនស្គាល់បំណងព្រះហឫទ័យរបស់ទ្រង់ដោយឯកឯងទេ។ យើងត្រូវការការបើកសំដែងមកពីព្រះបន្ទូល និងព្រះវិញ្ញាណរបស់ព្រះអង្គដើម្បីឱ្យដឹងថា ការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គមានអត្ថន័យយ៉ាងណា។ ទំនុកដំកើង ១១៩:៩៩-១០០ រំឭកយើងឱ្យសញ្ជឹងគិត និងធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ។ សុភាសិត ២:១-៥ ជំរុញយើងឱ្យទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីបានស្គាល់បំណងព្រះហឫទ័យរបស់ព្រះអង្គ។ យ៉ូហាន ១៦:១៣ បញ្ជាក់អះអាងថា ព្រះវិញ្ញាណបរិសុទ្ធគឺជាអ្នកនាំយើងចូលទៅក្នុងគ្រប់ទាំងសេចក្តីពិត។

អ្នកបម្រើរបស់អ័ប្រាហាំបានផ្តល់គំរូយ៉ាងល្អសម្រាប់យើង។ គាត់បានស្បថនឹងអ័ប្រាហាំថានឹងត្រលប់ទៅស្រុករបស់អ័ប្រាហាំដើម្បីរកប្រពន្ធឱ្យអ៊ីសាក។ គាត់បានធ្វើដំណើរចាកចេញទៅ ហើយនៅពេលដែលគាត់កំពុងតែធ្វើដំណើរទៅ ព្រះអម្ចាស់បានដឹកនាំគាត់។ គាត់មិនដឹងថាត្រូវធ្វើយ៉ាងណាដើម្បីរកឱ្យបានប្រពន្ធដែលព្រមត្រលប់មកស្រុកក្រៅ។ ដូច្នេះ នៅពេលដែលគាត់កំពុងតែធ្វើដំណើរទៅ គាត់បានបន្តស្វែងរកព្រះអម្ចាស់ ហើយគ្រប់ជំហានដែលគាត់ធ្វើដំណើរ ព្រះអម្ចាស់បានដឹកនាំគាត់ ហើយអ្នកបម្រើនោះបានដើរតាម (លោកុប្បត្តិ ២៤:៤៨)។ មានសេចក្តីពិតដែលសាមញ្ញមួយចំនួនសម្រាប់ឱ្យយើងរៀនចេញពីឧទាហរណ៍នេះ: ធ្វើដំណើរចេញទៅ ស្វែងរកព្រះអម្ចាស់នៅពេលដែលលោកអ្នកកំពុងធ្វើដំណើរ ស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ និងធ្វើតាមអ្វីដែលព្រះអង្គបង្ហាញលោកអ្នកឱ្យធ្វើ។ ប្រសិនបើលោកអ្នកមិនទាន់បានធ្វើដំណើរចេញទៅ ដោយស្តាប់បង្គាប់តាមអ្វីដែលលោកអ្នកបានយល់រួចមកហើយអំពីគោលបំណងរបស់ព្រះអង្គទេ នោះការស្វែងរកដើម្បីឱ្យបានស្គាល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មានផលប្រយោជន៍តិចតួចណាស់។

តើគ្រីស្ទបរិស័ទទាំងអស់នៅក្នុងសហគមន៍របស់លោកអ្នកស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់តាមរបៀបនេះដែរឬទេ គឺពិនិត្យមើលបទគម្ពីរ ឱ្យព្រះវិញ្ញាណដឹកនាំ និងធ្វើតាមអ្វីដែលពួកគេយល់អំពីអ្វីដែលព្រះអង្គកំពុងតែបង្ហាញពួកគេ? តើមានអ្វីកើតឡើង ប្រសិនបើអស់អ្នកដែលប្រកាសថាជាគ្រីស្ទបរិស័ទនៅក្នុងសហគមន៍របស់

លោកអ្នកស្វែងរកដើម្បីឱ្យបានស្គាល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ពេលដែលពួកគេសម្រេចចិត្តអំពីរបៀបដែលពួកគេត្រូវរស់នៅ បន្ទាប់មកធ្វើតាមអ្វីដែលព្រះវរបិតារបស់ពួកគេបានប្រាប់ពួកគេឱ្យធ្វើនោះ?

## គោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្ន

តើព្រះជាម្ចាស់ប្រាប់យើងនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គថា ព្រះអង្គចង់ឱ្យយើងធ្វើអ្វីនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង? មានកិច្ចការជាច្រើន! កិច្ចការ ១៤:២២ ជំរុញយើងឱ្យទ្រាំទ្រការលំបាក។ អេភេសូរ ៥:១៧-២០ ដាស់តឿនយើងកុំឱ្យស្រវឹងស្រា និងពេញដោយព្រះវិញ្ញាណ ច្រៀង និងអរព្រះគុណ។ ១ថែស្សាឡូនីច ៤:៣ និង ១១ ប្រាប់យើងឱ្យរស់នៅក្នុងជីវិតដែលបរិសុទ្ធ និងបង្កើតផល។ តើអស់អ្នកដែលហៅខ្លួនថាជាគ្រីស្ទបរិស័ទនៅក្នុងសហគមន៍របស់យើងទ្រាំទ្រការលំបាកដែរឬទេ? តើពួកគេមិនស្រវឹងស្រា ពេញដោយព្រះវិញ្ញាណ ច្រៀង និងអរព្រះគុណដែរឬទេ? តើពួកគេកំពុងតែរស់នៅក្នុងជីវិតដែលបរិសុទ្ធ និងបង្កើតផលដែរឬទេ? តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្តេចខ្លះសម្រាប់គ្រួសាររបស់យើង? នៅក្នុងអេភេសូរ ៥:២១ យើងត្រូវបានប្រាប់ឱ្យចុះចូល និងគោរពគ្នាទៅវិញទៅមក។ អេភេសូរ ៦:៤ ប្រាប់យើងឱ្យបង្រៀនកូនឱ្យរស់នៅបរិសុទ្ធ។ តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្តេចខ្លះសម្រាប់បងប្អូនគ្រីស្ទបរិស័ទរបស់យើង? នៅក្នុងយ៉ូហាន ១៣:៣៤ យើងត្រូវបានប្រាប់ឱ្យស្រលាញ់គ្នាទៅវិញទៅមក ហើយយ៉ូហាន ១៧:២០-២៣ ណែនាំយើងឱ្យរស់នៅរួបរួមគ្នា។ តើមានអ្វីកើតឡើង ប្រសិនបើគ្រីស្ទបរិស័ទទាំងអស់នៅក្នុងសហគមន៍របស់យើងបានស្វែងរកដើម្បីឱ្យបានស្គាល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយរស់នៅដូចដែលព្រះអង្គបង្គាប់នោះ? តើមានអ្វីកើតឡើង ប្រសិនបើយើងទាំងអស់គ្នារស់នៅដោយបរិសុទ្ធ បង្កើតផល និងគោរពគ្នាទៅវិញទៅមកទាំងនៅក្នុងជីវិតផ្ទាល់ខ្លួន ទាំងនៅក្នុងគ្រួសាររបស់យើង? តើមានអ្វីកើតឡើង ប្រសិនបើយើងរួបរួមគ្នាជាមួយអ្នកជឿដទៃទៀត? ប្រាកដជានឹងមានការផ្លាស់ប្តូរ!

តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្តេចសម្រាប់ទំនាក់ទំនងរបស់យើងជាមួយអ្នកដែលនៅក្នុងលោកិយ? នៅក្នុងរ៉ូម ១៣:៩ យើងត្រូវបានបង្គាប់ឱ្យស្រលាញ់អ្នកជិតខាងរបស់យើង។ នៅក្នុងយ៉ាកុប ១:២៧ យើងរៀនបានថា យើងត្រូវយកចិត្តទុកដាក់ចំពោះស្ត្រីមេម៉ាយ និងក្មេងកំព្រា។ នៅក្នុងយេរេមា ២២:៣, ១៥, ១៦ យើងរៀនបានថា ព្រះជាម្ចាស់រំពឹងថា យើងនឹងឧបត្ថម្ភគាំទ្រអ្នកដែលខ្វះខាត។ តើព្រះជាម្ចាស់មានគោលបំណងយ៉ាងដូចម្តេចសម្រាប់ទំនាក់ទំនងរបស់យើងជាមួយនិយោជក អ្នកបម្រើ រដ្ឋាភិបាល និងខ្មាំងសត្រូវ? កូល៉ុស ៤:១ ប្រាប់យើងឱ្យយុត្តិធម៌ត្រឹមត្រូវចំពោះអ្នកនៅក្រោមអំណាចរបស់យើង។ ១ពេត្រុស ២:១៣-១៥ បង្គាប់យើងឱ្យគោរពអ្នកមានអំណាចលើយើង រ៉ូម ១៣:១ ក៏ដាស់តឿនយើងឱ្យចុះចូលនឹងអ្នកមានអំណាច។ លូកា ៦:២៧, ៣៥ និង ៣៦ ណែនាំយើងឱ្យស្រលាញ់

ខ្មាំងសត្រូវរបស់យើង និងឱ្យពរពួកគេ។ តើគ្រីស្ទបរិស័ទទាំងអស់នៅក្នុងសហគមន៍របស់យើងរស់នៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងផ្នែកទាំងនេះដែរឬទេ? តើមានអ្វីកើតឡើង ប្រសិនបើនៅម៉ោង ៩ ថ្ងៃច័ន្ទក្រោយ អ្នកដែលហៅខ្លួនថាជាគ្រីស្ទបរិស័ទចាប់ផ្ដើមរស់នៅតាមរបៀបនេះ? វានឹងលើសពីការធ្វើបដិវត្តន៍ទៅទៀត វានឹងក្លាយទៅជាការផុសផុល! មនុស្សនឹងត្រូវបានទាញមកឯព្រះជាម្ចាស់!

ការស្ដាប់បង្គាប់របស់យើងមានឥទ្ធិពលទៅលើសពីទំនាក់ទំនងរបស់យើងជាមួយព្រះអម្ចាស់ទៅទៀត។ យើងប្រើរូបភាពនេះដើម្បីពន្យល់បង្ហាញអំពីសារៈសំខាន់នៃការស្ដាប់ បង្គាប់របស់យើងចំពោះគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគត។ មិនមែនតែព្រះជាម្ចាស់ប៉ុណ្ណោះទេ ដែលកំពុងតែសម្លឹងមើលយើង មនុស្សដែលបាក់បែកនៅក្នុងលោកិយក៏កំពុងតែសម្លឹងមើលយើងផងដែរ។ នៅពេលដែលយើងស្ដាប់បង្គាប់ព្រះជាម្ចាស់ យើងបង្ហាញចេញសេចក្ដីស្រលាញ់ និងព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះអង្គចំពោះពួកគេទាំងនៅពេលបច្ចុប្បន្ន និងនៅពេលអនាគត។ នេះគឺជារបៀបដែលគួរតែកើតមាន! នៅពេលដែលមនុស្សបាក់បែកនៅក្នុងសហគមន៍របស់យើងមើលមកយើង ពួកគេគួរតែអាចមើលឃើញគោលបំណងដ៏ល្អរបស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគត។




ពួកគេគួរតែមើលឃើញមិនត្រឹមតែគោលបំណងដ៏ល្អរបស់ព្រះអង្គសម្រាប់ពេលអនាគត ដែលជាព្រះគុណជួយសង្គ្រោះរបស់ព្រះជាម្ចាស់ និងការជួយសង្គ្រោះចេញពីសេចក្ដីស្លាប់អស់កល្បជានិច្ចប៉ុណ្ណោះទេ។ ពួកគេគួរតែមើលឃើញដំណឹងល្អដ៏អស្ចារ្យដែលព្រះជាម្ចាស់មានសម្រាប់ពួកគេ**នៅពេលឥឡូវនេះ**ផងដែរ។ ពួកគេគួរតែមើលឃើញសេចក្ដីនេះ ប៉ុន្តែជាញឹកញាប់ ពួកគេមិនអាចមើលឃើញបានទេ! ហេតុអ្វី? មានជញ្ជាំងមួយដែលបាំងពួកគេមិនឱ្យមើលឃើញ។ ជញ្ជាំងនោះគឺជាអំពើបាប។ យើងចូលចិត្តជឿថា អំពើបាបរបស់លោកិយរារាំងមនុស្សបាក់បែកនៅក្នុងសហគមន៍របស់យើងមិនឱ្យមើលឃើញគោលបំណងរបស់ព្រះជាម្ចាស់។ ទេ មិនមែនអំពើបាបរបស់លោកិយមួយប៉ុណ្ណោះទេ គឺមានអំពើបាប និងការមិនស្ដាប់បង្គាប់របស់យើងផងដែរ។ អំពើបាបនោះគឺជាការដែលយើងមិនព្រមរស់នៅតាមរបៀបដែលព្រះជាម្ចាស់ត្រាស់ហៅយើងឱ្យរស់នៅក្នុងពេលបច្ចុប្បន្ន ដែលតំណាងឱ្យគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពិភពលោកដែលបាក់បែកនៅជុំវិញយើង "ដូច្នេះ យើងខ្ញុំជាទូតដំណាងព្រះគ្រីស្ទ ហាក់ដូចជាព្រះទ្រង់អង្វរដោយសារយើងខ្ញុំ គឺយើងខ្ញុំអង្វរគេជំនួសព្រះគ្រីស្ទថា ចូរឱ្យបានជាមេត្រីនឹងព្រះចុះ" (២កូរិនថូស ៥:២០)។

ប្រសិនបើយើងគឺជាព្រះ តើលោកអ្នកនឹងធ្វើយ៉ាងដូចម្ដេចចំពោះជញ្ជាំងនោះ? ជាញឹកញាប់ មនុស្សឆ្លើយថា ពួកគេនឹងរម្លំជញ្ជាំងនោះ ហើយបំផ្លាញជញ្ជាំងនោះចោល! ចូរប្រយ័ត្ននឹងចម្លើយនោះ ពីព្រោះយើងកំពុងតែនិយាយអំពីខ្លួនឯង! យើងក៏ដឹងចេញបទគម្ពីរផងដែរថា រហូតដល់ពេលដែលព្រះយេស៊ូវយាងត្រលប់មកវិញ អំពើបាបនឹងមិនត្រូវបានដកចេញទាំងស្រុងចេញពីពិភពលោកទេ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់បានធ្វើកិច្ចការផ្សេងជាមួយជញ្ជាំងអំពើបាបដែលរារាំងមនុស្សលោកមិនឱ្យមើលឃើញគោលបំណងដ៏ល្អរបស់ព្រះអង្គ។ ព្រះអង្គបានដាក់បង្អួចនៅជាប់នឹងជញ្ជាំងនោះ! បង្អួចនោះគឺជាពួកជំនុំ គឺពួកជំនុំរបស់ព្រះយេស៊ូវគ្រីស្ទ។ ព្រះជាម្ចាស់មានបំណងថា នៅពេលដែលមនុស្សដែលបាក់បែកនៅក្នុងសហគមន៍របស់យើងមើលតាមបង្អួចដែលជាពួកជំនុំរបស់ព្រះអង្គ ពួកគេនឹងមើលឃើញបំណងល្អរបស់ព្រះអង្គសម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគត។

## ពួកជំនុំជាបង្អួច




យើងប្រើរូបភាពបង្អួចដែលមានកញ្ចក់បួនផ្ទាំងនៅក្នុងមេរៀននេះ។ ផ្ទាំងនិមួយៗតំណាងឱ្យផ្នែកមួយនៅក្នុងចំណោមផ្នែកទាំងបួនដែលព្រះយេស៊ូវបានរីកចម្រើនឡើង មាន "ប្រាជ្ញា" "ខាងសាច់ឈាម" "ខាងវិញ្ញាណ" និង"ខាងសង្គម"។ ដោយព្រោះព្រះយេស៊ូវបានរីកចម្រើនឡើងនៅក្នុងផ្នែកទាំងបួននេះ ចូរគិតថា ទាំងនេះក៏ជាផ្នែកដែលព្រះជាម្ចាស់យកចិត្តទុកដាក់សម្រាប់ការប្រោសមនុស្សឱ្យជា និងការរីកចម្រើនឡើង។ ពួកជំនុំគឺជាបង្អួចដែលតាមរយៈនោះមនុស្សបាក់បែកមើលឃើញគោលបំណងដ៏ល្អរបស់ព្រះជាម្ចាស់នៅក្នុងផ្នែកទាំងអស់នេះ។ តើពួកជំនុំមួយចំនួនធ្វើយ៉ាងដូចម្ដេចខ្លះជាមួយនឹងបង្អួចនេះ?

- ពួកជំនុំមួយចំនួនមើលមកផ្ទាំងកញ្ចក់ដែលសរសេរថា "ខាងសាច់ឈាម" រួចនិយាយថា "យើងមិនធ្វើព័ន្ធកិច្ចខាងសាច់ឈាមទេ យើងទុកឱ្យរដ្ឋាភិបាល និងទីភ្នាក់ងារបម្រើសុខុមាលភាពធ្វើផ្នែកនោះចុះ"។ នៅពេលដែលមានផ្នត់គំនិតនេះ ផ្ទាំងកញ្ចក់នោះបានស្រអាប់។ មនុស្សដែលបាក់បែកនៅក្នុងសហគមន៍របស់យើងមិនអាចមើលឃើញបានទេពីព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះសេចក្ដីត្រូវការខាងសាច់ឈាមតាមរយៈបង្អួច ដែលជាពួកជំនុំ។

- កញ្ចក់មួយផ្ទាំងផ្សេងទៀតតំណាងឱ្យគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ការប្រោសភាពបាក់បែកខាងសង្គមគ្រប់បែបយ៉ាងឱ្យបានជា។ ពួកជំនុំមួយចំនួនប្រហែលជានិយាយថា "នេះមិនមែនជាកិច្ចការរបស់យើងទេ។ យើងមិនពាក់ព័ន្ធការងារសង្គមទេ!" ផ្ទាំងកញ្ចក់នោះត្រលប់ជាស្រអាប់ ហើយមនុស្សដែលបាក់បែកមិនអាចមើលឃើញគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ការប្រោសសង្គមឱ្យជាតាមរយៈពួកជំនុំទេ។
- កញ្ចក់មួយផ្ទាំងផ្សេងទៀតតំណាងឱ្យប្រាជ្ញា។ ពួកជំនុំប្រហែលជានិយាយថា "យើងពាក់ព័ន្ធនៅក្នុងប្រាជ្ញា ប៉ុន្តែសម្រាប់តែអ្នកនៅក្នុងពួកជំនុំតែប៉ុណ្ណោះ។ ពួកគេត្រូវតែចូល *មកក្នុង*ពួកជំនុំ មុនពេលដែលពួកគេអាចរៀនអំពីប្រាជ្ញារបស់ព្រះជាម្ចាស់បាន"។ នៅពេលដែលការនោះកើតឡើង កញ្ចក់មួយផ្ទាំងនេះបានស្រអាប់។ អ្នកនៅក្រៅពួកជំនុំមិនអាចមើលឃើញគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ការរីកចម្រើនឡើងរបស់ពួកគេខាងឯប្រាជ្ញាបានទេ។
- កញ្ចក់ផ្ទាំងចុងក្រោយរបស់បង្អួចគឺជាផ្ទាំងកញ្ចក់ខាងវិញ្ញាណ។ ពួកជំនុំប្រហែលជានិយាយថា "មែនហើយ! យើងត្រូវបានត្រាស់ហៅឱ្យប្រកាសដំណឹងល្អខាងវិញ្ញាណ!" នៅពេលដែលមនុស្សបាក់បែកនៅក្នុងសហគមន៍មើលតាមរយៈបង្អួចដែលជាពួកជំនុំ តើសេចក្តីតែមួយគត់ដែលពួកគេមើលឃើញគឺជាអ្វី ប្រសិនបើផ្ទាំងកញ្ចក់ខាងសាច់ឈាម ខាងសង្គម និងខាងប្រាជ្ញាបានស្រអាប់ហើយនោះ? ពួកគេមើលឃើញតែគោលបំណងខាងវិញ្ញាណរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ផ្នែកខាងវិញ្ញាណមានសារៈសំខាន់យ៉ាងធំធេងទាំងនៅពេលបច្ចុប្បន្ន និង នៅពេលអនាគត ប៉ុន្តែមនុស្សដែលបាក់បែកប្រហែលជាមិនដឹងសេចក្តីនេះទេ។ ពួកគេប្រហែលជាដូចជាជូអាន ជាបុរសវ័យក្មេងដែលរូឌីបានជួបនៅក្នុងតំបន់ក្រីក្រអនាធិបតេយ្យក្នុងក្រុងលីម៉ា ប្រទេសពេរូ។ គាត់បានហែក និងបានលេបខិតប័ណ្ណដែលរូឌីបានឱ្យគាត់។ ដើម្បីឱ្យបានយល់ច្បាស់ គាត់បាននិយាយថា "ខ្ញុំមិនចាប់អារម្មណ៍នឹងដំណឹងល្អខាងវិញ្ញាណសម្រាប់ពេលអនាគតទេឥឡូវនេះ ខ្ញុំឃ្លាន! តើព្រះរបស់អ្នកយកព្រះហឫទ័យទុកដាក់ចំពោះខ្ញុំជាអ្នកគ្មានការងារ និងស្រេកឃ្លាននៅពេលឥឡូវនេះដែរឬទេ?"។



ពួកជំនុំរបស់យើងត្រូវសម្ងាតបង្អួចរបស់ពួកគេ! មនុស្សដែលបាក់បែកត្រូវតែមើលឃើញតាមផ្ទាំងកញ្ចក់ទាំងអស់។ ព្រះជាម្ចាស់ចង់ឱ្យជូអាន និងបងប្អូនទាំងអស់របស់គាត់ដែលបាក់បែកឱ្យអាចមើលឃើញបានតាមបង្អួចដែលជាពួកជំនុំ ហើយឃើញគោលបំណងដ៏ល្អរបស់ព្រះជាម្ចាស់សម្រាប់ពួកគេនៅគ្រប់ផ្នែកទាំងអស់ ទាំងខាងសាច់ឈាម ខាងវិញ្ញាណ ខាងសង្គម និងប្រាជ្ញា។

មានការស្ទង់មតិក្រៅផ្លូវការនៅតាមផ្លូវប្រជុំជនមួយនៅក្នុងសហរដ្ឋអាមេរិក។ មនុស្សជាច្រើនត្រូវបានសួរថា "ប្រសិនបើអ្នកកំពុងប្រឈមមុខនឹងវិបត្តិដ៏ធំនៅក្នុងជីវិត តើអ្នកនឹងបែរទៅឯណាដើម្បីឱ្យបានជំនួយ?"។ គ្មាននរណាម្នាក់បានលើកឡើងអំពីពួកជំនុំទេ! មនុស្សមិនស្គាល់ពួកជំនុំដូចជាពួកជំនុំដែលព្រះយេស៊ូវចង់បានទេ។ ប្រសិនបើពួកជំនុំរបស់អ្នកបិទទ្វារនៅថ្ងៃស្អែក តើសហគមន៍របស់អ្នកនឹងខ្វល់ខ្វាយដែរឬទេ?។ តើពួកគេនឹងកត់សម្គាល់ឃើញដែរឬទេ?

ពីរបីឆ្នាំមុន លោកបប់កំពុងបង្រៀនអ្នកដឹកនាំពួកជំនុំនៅកោះមីនដាណាវ ប្រទេសហ្វីលីពីន ហើយនៅលើកោះនោះ ភាគច្រើនជាអ្នកកាន់សាសនាអ៊ីស្លាម។ មានភាពតានតឹងយ៉ាងខ្លាំងរវាងអ្នកកាន់សាសនាអ៊ីស្លាម និងអ្នកមិនកាន់សាសនាអ៊ីស្លាម។ នៅថ្ងៃចុងក្រោយនៃសិក្ខាសាលា មនុស្សដប់នាក់ស្លៀកពាក់ជាអ្នកកាន់សាសនាអ៊ីស្លាម បានចូលមកក្នុងពួកជំនុំដែលពួកគេបានជួបជុំគ្នា។ សិក្ខាកាមមានទឹកមុខតក់ស្លុត។ អ្នករៀបចំសិក្ខាសាលាបានរកឃើញថា ទាំងនេះគឺជាអ្នកជឿថ្មី ដែលត្រូវបានពន្យាលពេលបួនថ្ងៃនៅកន្លែងត្រួតពិនិត្យរបស់ទាហាន ពេលដែលធ្វើដំណើរមកចូលរួមសិក្ខាសាលា។ ពួកគេបាននិយាយប្រាប់រឿងរបស់ពួកគេ។ អស់រយៈពេលជាច្រើនឆ្នាំ មានគ្រីស្ទបរិស័ទបានមកកាន់ភូមិរបស់ពួកគេ ប្រកាសដំណឹងល្អ និងចែកខិតប័ណ្ណ។ អ្នកភូមិបានបដិសេធព្រះរាជសារ។ នៅពេលថ្មីៗនេះ មានមនុស្សមួយក្រុមបានមកកាន់ភូមិរបស់ពួកគេ ដើម្បីជួយអ្នកដែលមានសេចក្តីត្រូវការដោយសេចក្តីស្រលាញ់។ ក្រោយមក អ្នកភូមិបានដឹងថា អ្នកយកចិត្តទុកដាក់នឹងគេទាំងនេះគឺជាគ្រីស្ទបរិស័ទ។ ឥទ្ធិពលរបស់ព័ន្ធកិច្ចនេះមានអំណាចយ៉ាងខ្លាំងធ្វើឱ្យអ្នកភូមិទាំងនេះជឿព្រះគ្រីស្ទ។ ពាក្យសំដីរបស់អ្នកនិយាយចុងក្រោយ ដែលជាក្មេងស្រីជំទង់ គឺជាពាក្យប្រកបដោយប្រាជ្ញាសម្រាប់យើង។ គ្រីស្ទបរិស័ទបានមកកាន់ភូមិរបស់នាងផ្សាយដំណឹងល្អតាមបែបទំនៀមទម្លាប់អស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែមានតែពេលដែលដំណឹងល្អខ្ចប់នៅក្នុងសេចក្តីស្រលាញ់ និងការប្រព្រឹត្តិល្អប៉ុណ្ណោះ ទើបដំណឹងល្អច្រូតបានផល។ នាងបានបញ្ចប់ជាមួយនឹងសំណួរដែលមិនអាចភ្លេចបាន "តើអ្វីបានធ្វើឱ្យអ្នកនៅយូរម្លេះ?"។

## រូបភាពរបស់ពួកជំនុំ

តើអ្វីធ្វើឱ្យយើងនៅយូរម្លេះ? នោះគឺជាអំពើបាប និងការមិនស្តាប់បង្គាប់របស់យើង។ ផែនការរបស់ព្រះជាម្ចាស់សម្រាប់ពួកជំនុំគឺអស្ចារ្យខ្លាំងណាស់! មានការប្រៀបធៀបជាច្រើនដែលលោកប៉ុល ព្រះយេស៊ូវ និងលោកពេត្រុសបានប្រើដើម្បីពណ៌នាអំពីពួកជំនុំ។ (ការប្រៀបធៀបគឺជាពាក្យរូបភាព)។

- ពួកជំនុំគឺជា***សង្ឃ***។ ជនជាតិអ៊ីស្រាអែលត្រូវធ្វើជាសង្ឃដល់គ្រប់ទាំងសាសន៍ ហើយពួកជំនុំនៅសព្វថ្ងៃនេះ គឺដូចដែលព្រះជាម្ចាស់ចង់ឱ្យជនជាតិអ៊ីស្រាអែលធ្វើនៅក្នុងសញ្ញាចាស់។ យើងត្រូវធ្វើជាសង្ឃដល់អ្នកនៅក្រៅពួកជំនុំ។ នៅពេលដែលពួកគេមើលមក ពួកគេគួរតែមើលឃើញយើងស្តាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងតំណាងឱ្យព្រះអង្គ។
- ពួកជំនុំគឺជា ***អំបិល និងពន្លឺ*** ។ ជាញឹកញាប់ យើងសួរមនុស្សជាច្រើនក្រុមថា "តើអ្នកចូលចិត្តអំបិលដែរឬទេ?" ស្ទើរតែគ្រប់គ្នាទាំងអស់ចូលចិត្ត! បន្ទាប់មក យើងនិយាយថា "ខ្ញុំចង់ពិសោធន៍អ្នក។ នៅពេលអ្នកបរិភោគអាហារលើកក្រោយ សូមយកអំបិលមួយស្លាបព្រាបាយ ហើយបរិភោគ"។ ភ្លាមនោះ មុខរបស់ពួកគេមានប្រតិកម្ម! "អ្នកមិនចូលចិត្តទេឬ? ខ្ញុំគិតថា អ្នកបានប្រាប់ថា អ្នកចូលចិត្តអំបិល។ អូហ៍ អ្នកចូលចិត្តអំបិល ប៉ុន្តែអ្នកមិនចូលចិត្តអំបិលផ្ដុំគ្នាទេ! អ្នកចង់ឱ្យអំបិលរោយជុំវិញ!"។ ជាញឹកញាប់ ពួកជំនុំរបស់យើងប្រៀបបីដូចជាអំបិលមួយស្លាបព្រា នៅផ្ដុំគ្នា។ ព្រះជាម្ចាស់មានបន្ទូលថា "ចូរចេញពីស្លាបព្រា! ចូលទៅក្នុងសហគមន៍ទៅ! ហើយរោយពាសពេញទីនោះទៅ!"។
- ពួកជំនុំគឺជា ***ស្ថានទូតនគរព្រះ*** ។ ព្រះយេស៊ូវបានចាត់សិស្សរបស់ព្រះអង្គឱ្យចេញទៅជាទូតរបស់ព្រះអង្គដូច្នេះហើយ ពួកជំនុំរបស់យើងគឺជាស្ថានទូត។ ដូចដែលយើងបានដឹងរួចមកហើយ ស្ថានទូតតំណាងឱ្យគោលបំណងរបស់រដ្ឋាភិបាលដែលពួកគេតំណាងឱ្យ។ យើងត្រូវតំណាងឱ្យគោលបំណងរបស់នគរយើង។
- ពួកជំនុំគឺជា ***សំបុត្រ*** ។ លោកប៉ុលបានសរសេរថា យើងប្រៀបបីដូចជាសំបុត្រដែលបើក ហើយមនុស្សគ្រប់គ្នាទាំងអស់អាន។ មនុស្សពិបាកនឹងអានសំបុត្ររបស់ព្រះជាម្ចាស់ណាស់ នៅពេលដែលពួកគេមើលជីវិតរបស់យើង។ យើងត្រូវធ្វើជាសំបុត្រ*ដែលមានតម្លៃតាមផ្លូវច្បាប់* ដែលបង្ហាញដំណឹងល្អរបស់ព្រះជាម្ចាស់សម្រាប់ពេលបច្ចុប្បន្ន!
- ពួកជំនុំក៏ជា ***អ្នកបម្រើដែលស្តាប់បង្គាប់ អ្នកជិតខាងសប្បុរស និងរស់ជាតិដំបូងនៃសេចក្តីដែលពិសេស*** ។ លោក បប់ មានដើមទំពាំងបាយជូរនៅខាងក្រោយផ្ទះរបស់គាត់។ នៅចុងរដូវត្រជាក់ ទំពាំងបាយជូរចាប់ផ្ដើមទុំ។ គាត់រកមើលផ្លែទំពាំងបាយជូរដំបូងគេដែលទុំ ហើយល្មមនឹងបរិភោគ។ គាត់រកឃើញហើយបេះវាមក និងបកសំបកចេញ។ គាត់ចង់បរិភោគផ្លែទំពាំងបាយជូរដំបូងនោះណាស់។ វាមានរស់ជាតិឆ្ងាញ់! បន្ទាប់មក គាត់ដឹងថា ផ្លែទំពាំងបាយជូរផ្សេងទៀតនឹងមានរស់ជាតិបែបណា នៅពេលវាទុំ។ នោះគឺជាផ្លែដំបូង។ ប៉ុន្តែ ពេលខ្លះ យើងគឺជាផ្លែដែលមិនទាន់ទុំ។ ពេលដែលលោកិយបរិភោគយើងទៅ មាន

រស់ជាតិល្វីង។ ពួកគេខ្ទាក់យើងចេញមកវិញ។ ប៉ុន្តែព្រះជាម្ចាស់ចង់ឱ្យយើងធ្វើជាផ្លែដំបូងដែលមានរស់ជាតិឆ្ងាញ់ គឺជារស់ជាតិដំបូងអំពីនគរព្រះអង្គ។

មានរូបភាពដទៃទៀតអំពីពួកជំនុំ ដែលយើងមិនបាននិយាយនៅក្នុងមេរៀននេះ។ ពួកជំនុំគឺជារូបកាយរបស់ព្រះគ្រីស្ទ។ ក្នុងនាមជារូបកាយ ពួកជំនុំគួរតែសម្រេចគោលបំណងរបស់ក្បាល គឺជាព្រះយេស៊ូវគ្រីស្ទ ហើយអវយវៈនិមួយៗមានតួនាទីជាក់លាក់មួយនៅក្នុងរូបកាយនេះ។ ពួកជំនុំក៏ជាកូនក្រមុំរបស់ព្រះគ្រីស្ទផងដែរ។ ព្រះជាម្ចាស់ស្រលាញ់ពួកជំនុំដោយសេចក្តីស្រលាញ់ដែលគ្មានដែនកំណត់។ ទំនាក់ទំនងដ៏ស្និទ្ធស្នាលរវាងព្រះគ្រីស្ទ និងកូនក្រមុំរបស់ព្រះអង្គ ផ្តល់ការបណ្តាលចិត្តយ៉ាងខ្លាំងដើម្បីឱ្យពួកជំនុំធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ។ ពួកជំនុំក៏ជារបៀបវារៈរបស់ព្រះជាម្ចាស់ ដើម្បីប្រោសពិភពលោកដែលបាក់បែកឱ្យបានជាផងដែរ។ ពួកជំនុំគឺជាអ្នកប្រាប់ និងជាអ្នកសម្របសម្រួលរបៀបវារៈនោះ និងបណ្តុះបណ្តលសមាជិករបស់ខ្លួនឱ្យទៅគ្រប់ជ្រុងនៅក្នុងសង្គម ដើម្បីធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ជាការសំខាន់ខ្លាំងណាស់ដែលត្រូវអនុវត្តអ្វីដែលយើងរៀន! ជាញឹកញាប់ យើងសូមសិស្សឱ្យគូរបង្អួចមួយ ដាក់ឈ្មោះផ្ទាំងកញ្ចក់និមួយៗតាមផ្នែកនិមួយៗនៃផ្នែកទាំងបួនដែលព្រះយេស៊ូវរីកចម្រើនឡើង។ កត់ត្រាសកម្មភាពថ្មីពីរនៅក្នុងផ្នែកនិមួយៗ ដែលពួកជំនុំរបស់គេអាចធ្វើបាន ដើម្បីបង្ហាញចេញគោលបំណងនៅពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់នៅក្នុងសហគមន៍របស់ពួកគេ ហើយប្តេជ្ញាចិត្តនឹងពិភាក្សាអំពីគំនិតទាំងនេះជាមួយអ្នកដឹកនាំពួកជំនុំរបស់ពួកគេ។ នៅពេលដែលលោកអ្នកអានការណែនាំនេះ លោកអ្នកអាចធ្វើកិច្ចការនេះបានផងដែរ។

មានខ្យល់ជំនោរថ្មីបក់ចូលមកក្នុងពួកជំនុំនៅសព្វថ្ងៃនេះ នៅពេលដែលពួកគេរៀនធ្វើជាទូតតំណាងឱ្យគោលបំណងពេញលេញរបស់ព្រះជាម្ចាស់! ខ្យល់ជំនោរថ្មីនេះមានសញ្ញាសំគាល់របស់ព្រះវិញ្ញាណបរិសុទ្ធ បង្កើតឱ្យមានចិត្តឆេះឆួលចង់បង្ហាញចេញរបៀបវារៈពេញលេញរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោកដែលបាក់បែក។ មានបុគ្គល និងពួកជំនុំខ្លះ ក្តោងរបស់ពួកគេកំពុងប៉ះខ្យល់ជំនោរនោះ។ យើងខ្ញុំសូមអធិស្ឋានឱ្យព្រះជាម្ចាស់ប្រើពួកគេដើម្បីប្រែក្លាយខ្យល់ជំនោរឱ្យទៅជាខ្យល់បក់យ៉ាងខ្លាំង។ អ្នកនៅក្នុងពួកជំនុំគួរតែជាទីបន្ទាល់ដ៏ជាក់ច្បាស់អំពីសេចក្តីស្រលាញ់របស់ព្រះគ្រីស្ទសម្រាប់ភាពបាក់បែកខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គម ដើម្បីឱ្យមនុស្សទាំងអស់ដែលមើលតាមរយៈបង្អួចដែលជាពួកជំនុំ នាំគ្នានិយាយថា "អ្នកទាំងនេះមានព្រះដ៏ធំឧត្តម និងជាព្រះមានសេចក្តីស្រលាញ់យ៉ាងអស្ចារ្យ!"[១]។

---

[1] សេចក្តីជាច្រើននៅក្នុងមេរៀននេះដកស្រង់ផ្ទាល់ចេញពី *ប្រសិនបើព្រះយេស៊ូវគឺជាចៅហ្វាយក្រុង* សរសេរឡើងដោយ បប់ ម៉ូហ៊្វិត និងមានការអនុញ្ញាតឱ្យប្រើ។

*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ  85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាត: លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាម ទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១000 ច្បាប់ ។*

## ធនធានល្អដែលបានផ្តល់ជាយោបល់ជូនៈ

Harvest Website: www.harvestfoundation.org . Sections: Materials: LDTP II Section 14-1 "What Kind of Churches?" and Local Church Ministry Training (LCMT) Part 2

Disciple Nations Alliance online course: www.disciplenations.org/resources/course. Section: Wholistic Ministry

*If Jesus Were Mayor*, Bob Moffitt and Karla Tesch, Chapter 13 pp. 312-316 and pp. 27-30, 33-34.